តើអ្នកអាចទទួលបានជំនួយដើម្បីបង់ប្រាក់ធានារ៉ាប់រងសុខភាពតាមរយៈ Health Connector ដែរឬទេ?

MASSACHUSETTS HEALTH CONNECTOR

អ្នកអាចមានលក្ខណៈគ្រប់គ្រាន់ ប្រសិនបើអ្នក៖

- ☑ ទិញទំនិញតាមរយៈ Massachusetts Health Connector
- ☑ រស់នៅរដ្ឋ Massachusetts
- ☑ ជាពលរដ្ឋអាមេរិក មានសញ្ជាតិ ឬមានវត្តមានដោយស្របច្បាប់នៅក្នុងសហរដ្ឋអាមេរិក។
- ☑ មានកម្រិតប្រាក់ចំណូលដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ទំហំគ្រួសាររបស់អ្នក។

ចំណាំ៖ សម្រាប់គម្រោង ConnectorCare កម្រិតប្រាក់ចំណូលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់គឺ ចន្លោះពី 100% ទៅ 400% នៃកម្រិតភាពក្រីក្រសហព័ន្ធ (FPL) ឬទាបជាងនេះ (សូមមើលតារាងខាងក្រោម)។

អ្នកនឹងមិនអាចមានលក្ខណៈគ្រប់គ្រាន់ទេ ប្រសិនបើអ្នក៖

- ☒ ទទួលបានការធានារ៉ាប់រងតាមរយៈ Medicare, MassHealth (Medicaid) ឬកម្មវិធីធានារ៉ាប់រងសុខភាពសាធារណៈផ្សេងទៀត
- ☒ នៅក្នុងគុក ឬពន្ធនាគារនៅពេលនេះ
- ☒ ត្រូវបានផ្តល់ជូនការធានារ៉ាប់រងសុខភាពគ្រប់ជ្រុងជ្រោយដែលមានតម្លៃសមរម្យពីនិយោជក។

ចំណាំ៖ ប្រសិនបើតម្លៃនៃគម្រោងធានារ៉ាប់រងសុខភាពរបស់និយោជករបស់អ្នកសម្រាប់មនុស្សម្នាក់ៗគឺច្រើនជាង 10.22% នៃប្រាក់ចំណូលគ្រួសារប្រចាំឆ្នាំរបស់អ្នកសម្រាប់ឆ្នាំ 2027 នោះការធានារ៉ាប់រងនោះមិនត្រូវបានចាត់ទុកថាមានតម្លៃសមរម្យនោះទេ។

គោលការណ៍ណែនាំស្តីពីប្រាក់ចំណូលប្រចាំឆ្នាំ 2026* ដោយផ្អែកលើកម្រិតភាពក្រីក្ររបស់សហព័ន្ធ (Federal Poverty Level, FPL)

ទំហំគ្រួសារ	គម្រោង ConnectorCare Plan ប្រភេទ 2A (100-150% FPL)	គម្រោង ConnectorCare Plan ប្រភេទ 2B (150-200% FPL)	គម្រោង ConnectorCare Plan ប្រភេទ 3A (200-250% FPL)	គម្រោង ConnectorCare Plan ប្រភេទ 3B (250-300% FPL)	គម្រោង ConnectorCare Plan ប្រភេទ 3C (300-400% FPL)
1	$15,960–$23,940	$23,940–$31,920	$31,920–$39,900	$39,900–$47,880	$47,880–$63,840
2	$21,640–$32,460	$32,460–$43,280	$43,280–$54,100	$54,100–$64,920	$64,920–$86,560
3	$27,320–$40,980	$40,980–$54,640	$54,640–$68,300	$68,300–$81,960	$81,960–$109,280
4	$33,000–$49,500	$49,500–$66,000	$66,000–$82,500	$82,500–$99,000	$99,000–$132,000
បុព្វលាភប្រចាំខែទាបបំផុតក្នុងមនុស្សម្នាក់ៗ	$8,520	$11,360	$14,200	$17,040	$22,720
បុព្វលាភប្រចាំខែទាបបំផុតក្នុងមនុស្សម្នាក់ៗ*	$0	$55	$107	$158	$242

*កម្រិតភាពក្រីក្រសហព័ន្ធឆ្នាំ 2026 ត្រូវបានប្រើដើម្បីកំណត់ថាតើអ្នកណាអាចមានសិទ្ធិទទួលបានគម្រោង Health Connector ឬ ConnectorCare ក្នុងអំឡុងឆ្នាំគម្រោង 2027 ចាប់ពីថ្ងៃទី 1 ខែមករា ដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2027។

ប្រសិនបើអ្នកបំពេញតាមតម្រូវការទាំងនេះ អ្នកប្រហែលជាអាចទទួលបានជំនួយដើម្បីបង់ប្រាក់ធានារ៉ាប់រងសុខភាព។
ចូលទៅកាន់ MAhealthconnector.org ដើម្បីប្រើប្រាស់ឧបករណ៍ "Get an Estimate" (ទទួលបានការប៉ាន់ស្មាន) ដើម្បីមើលគម្រោងសុខភាព និងតម្លៃជាមុន។

ATTENTION: If you speak another language, there are free language assistance services available to you. Call 1-877-623-6765 (TTY: 711).

គម្រោង ConnectorCare Plan និងឥណទានពន្ធលើថ្លៃធានារ៉ាប់រងជាមុន

គម្រោង ConnectorCare មានថ្លៃបង់ធានារ៉ាប់រងប្រចាំខែដែលទាប ឬ $0 ការចំណាយចេញពីហោប៉ៅទាប និងគ្មានប្រាក់បង់មុននោះទេ។ អ្នកដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានឥណទានពន្ធលើថ្លៃធានារ៉ាប់រងជាមុនរបស់សហព័ន្ធ បូករួមទាំងប្រាក់សន្សំបន្ថែមរបស់រដ្ឋ Massachusetts ដែលត្រូវបានអនុវត្តលើវិក្កយបត្រប្រចាំខែរបស់អ្នក និងជួយកាត់បន្ថយថ្លៃបង់ធានារ៉ាប់រងសុខភាពរបស់អ្នក។

- សម្រាប់គ្រួសារដែលមានប្រាក់ចំណូលចន្លោះពី 100% ទៅ 400% នៃ FPL។
- ឥណទានពន្ធផ្អែកលើប្រាក់ចំណូលរបស់អ្នក ទំហំគ្រួសារ និងទីតាំងដែលអ្នករស់នៅ។
- ប្រភេទនៃគម្រោង ConnectorCare Plan ដែលអ្នកអាចមានលក្ខណសម្បត្តិគ្រប់គ្រាន់ក៏ផ្អែកលើ FPL នៃគ្រួសាររបស់អ្នកផងដែរ។
- អាស្រ័យលើទីតាំងដែលអ្នករស់នៅ អ្នកប្រហែលជាអាចជ្រើសរើសពីក្រុមហ៊ុនធានារ៉ាប់រងផ្សេងៗគ្នារហូតដល់ប្រាំបីក្រុមហ៊ុន។

អត្ថប្រយោជន៍ទាំងអស់ដែលរ៉ាប់រងដោយគម្រោង ConnectorCare គឺដូចគ្នា។ ការចំណាយនឹងប្រែប្រួលទៅតាមប្រភេទនៃគម្រោង។ បណ្តាញអ្នកផ្តល់សេវា (វេជ្ជបណ្ឌិត និងមន្ទីរពេទ្យដែលរ៉ាប់រងដោយគម្រោង) ខុសគ្នាទៅតាមក្រុមហ៊ុនធានារ៉ាប់រង។

ថ្លៃបង់ធានារ៉ាប់រងប្រចាំខែរបស់ ConnectorCare ក្នុងមនុស្សម្នាក់អាចទាបដល់ទៅ៖

- **$0** ក្នុងមួយខែសម្រាប់គម្រោងប្រភេទ 2A
- **$55** ក្នុងមួយខែសម្រាប់គម្រោងប្រភេទ 2B
- **$107** ក្នុងមួយខែសម្រាប់គម្រោងប្រភេទ 3A
- **$158** ក្នុងមួយខែសម្រាប់គម្រោងប្រភេទ 3B
- **$242** ក្នុងមួយខែសម្រាប់គម្រោងប្រភេទ 3C

អាស្រ័យលើទីតាំងដែលអ្នករស់នៅ អ្នកប្រហែលជាអាចជ្រើសរើសគម្រោង ConnectorCare ពី៖

- Blue Cross Blue Shield of Massachusetts
- Fallon Health
- Harvard Pilgrim Health Care
- Health New England
- Mass General Brigham Health Plan
- Tufts Health Plan
- UnitedHealthcare
- WellSense Health Plan

ឧទាហរណ៍នៃប្រាក់សន្សំ ConnectorCare៖

Jim មានអាយុ 45 ឆ្នាំ រស់នៅក្នុងទីក្រុង Boston ហើយរកចំណូលបាន $35,000 ក្នុងមួយឆ្នាំ។ គាត់មានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់គម្រោង ConnectorCare ប្រភេទ 3A ជាមួយនឹងឥណទានពន្ធចំនួន $366។ Jim ជ្រើសរើសគម្រោង ConnectorCare ដែលមានតម្លៃទាបបំផុតដែលមាននៅក្នុងតំបន់របស់គាត់ បន្ទាប់ពីពិនិត្យមើលដើម្បីធានាថា វេជ្ជបណ្ឌិតថែទាំសុខភាពបឋមរបស់គាត់ត្រូវបានរ៉ាប់រងនៅក្នុងបណ្តាញអ្នកផ្តល់សេវារបស់ខ្លួន។

ថ្លៃបង់ធានារ៉ាប់រងប្រចាំខែរបស់ Jim គឺត្រឹមតែ $107 ក្នុងមួយខែប៉ុណ្ណោះ។ ដោយសារតែគាត់គឺជាសមាជិកនៃគម្រោង ConnectorCare គាត់មិនត្រូវទូទាត់ប្រាក់បង់មុននោះទេ ហើយចំណាយចេញពីហោប៉ៅសម្រាប់ទំនិញនានាដូចជាថ្នាំតាមវេជ្ជបញ្ជា ក៏ដូចជាទឹកប្រាក់បង់រួមនៅពេលគាត់ទៅជួបពិគ្រោះជាមួយវេជ្ជបណ្ឌិត ក៏តិចជាងមុនដែរ។

ត្រូវការជំនួយមែនទេ?

អ្នកអាចទទួលបានជំនួយផ្ទាល់ដោយឥតគិតថ្លៃដោយប្រើសេវាអ្នកផ្តល់ជំនួយក្នុងការចុះឈ្មោះនៅអង្គភាពសហគមន៍ដែគូដែលនៅជិតអ្នក។ អ្នកផ្តល់ជំនួយក្នុងការចុះឈ្មោះគឺជាអ្នកដែលត្រូវបានបណ្តុះបណ្តាលដើម្បីជួយអ្នកក្នុងការដាក់ពាក្យ និងចុះឈ្មោះតាមរយៈ Health Connector។

អ្នកអាចស្វែងរកបញ្ជីពេញលេញនៃទីតាំងដើម្បីទទួលបានជំនួយផ្ទាល់តាមរយៈ **MAhealthconnector.org/here-to-help**

Massachusetts Health Connector អនុវត្តតាមច្បាប់សិទ្ធិពលរដ្ឋសហព័ន្ធ និងរដ្ឋដែលអាចអនុវត្តបាន ហើយមិនរើសអើងដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិ ឬពូជពង្ស ភេទ អាយុ ពិការភាព ស្ថានភាពសុខភាព គុណភាពជីវិត ឬជំនឿសាសនាឡើយ។